## សម្រាប់ព័ត៌មានបន្ថែមអំពីសំណងនិយោជិក

- ទូរស័ព្ទទៅលេខ 800-323-3249 ឬ 617-717-4900 x7470 ។ អាចទទួលបានការបកប្រែភាសា ។
- ចូលទៅកាន់ **www.mass.gov/dia** ។
- អ៊ីម៉ែល **Info2@massmail.state.ma.us** ។
- ទៅកាន់មួយក្នុងចំណោមការិយាល័យទាំងប្រាំរបស់យើងខ្ញុំ ។

**តើក្រសួងគ្រប់គ្រងគ្រោះថ្នាក់ឧស្សាហកម្ម (Department of Industrial Accidents - DIA) គឺជាអ្វី?** DIA ត្រួតពិនិត្យប្រព័ន្ធសំណងនិយោជិកនៅក្នុងរដ្ឋម៉ាស្សាឈូសិត ។ DIA អាចជួយ ប្រសិនបើអ្នកគឺជានិយោជិកដែលរងរបួស និយោជកនៃ រដ្ឋកាលីហ្វ័រញ៉ា ក្រុមហ៊ុនធានារ៉ាប់រង ឬមេធាវី ។




ខុម៉ុនវែលម៉ាស្សាឈូសិត
(Commonwealth of Massachusetts)

ការិយាល័យប្រតិបត្តិការងារ និងអភិវឌ្ឍន៍កម្មករ
(Executive Office of Labor and Workforce Development)
ក្រសួងគ្រប់គ្រងគ្រោះថ្នាក់ឧស្សាហកម្ម
1 Congress Street, Suite 100
Boston, MA 02114-2017
617-727-4900 x7470 or 800-323-3249
www.mass.gov/dia


### ការិយាល័យធំ

1 Congress Street, Suite 100
Boston, MA 02114-2017
617-727-4900 x7470 or 800-323-3249

### ការិយាល័យតាមតំបន់

1 Father DeValles Boulevard, 3rd Floor
Fall River, MA 02723
508-676-3406

354 Merrimack Street, Building 1, Suite 230
Lawrence, MA 01843
978-683-6420

436 Dwight Street, Room 105
Springfield, MA 01103
413-784-1133

340 Main Street, 3rd Floor
Worcester, MA 01608
508-753-2072

2505 Rev-6-15

# រងរបួសនៅពេលធ្វើការងារ?

# សំណងនិយោជិក អាចជួយបាន




**ការិយាល័យប្រតិបត្តិការងារ និងអភិវឌ្ឍន៍កម្មករ**
**(Executive Office of Labor and Workforce Development)**
**ក្រសួងគ្រប់គ្រងគ្រោះថ្នាក់ឧស្សាហកម្ម**
**(Department of Industrial Accidents)**
(617) 727-4900 x7470 ឬ 800-323-3249
**www.mass.gov/dia**

## តើសំណងនិយោជិកគឺជាអ្វី?

ប្រសិនបើអ្នកមានបញ្ហាសុខភាព ឬការរងរបួស ដោយសារការងាររបស់អ្នក អ្នកប្រហែលអាចទទួលបានអត្ថប្រយោជន៍ស្ថិតក្រោមសំណងនិយោជិក ។

## តើអត្ថប្រយោជន៍នៃសំណងនិយោជិករ៉ាប់រងអ្វីខ្លះ?

- **វិក្កយប័ត្រវេជ្ជសាស្ត្រ** វេជ្ជបញ្ជា និងការរួមបង់ចំណាយ ។
- **ប្រាក់ឈ្នួលដែលបាត់បង់** (មួយផ្នែក) ប្រសិនបើអ្នកមិនអាចធ្វើការរយៈពេលប្រាំថ្ងៃឡើងទៅ ដោយសារការរងរបួស ឬជម្ងឺពាក់ព័ន្ធនឹងការងារ ។
- **ចំណាយថ្លៃធ្វើដំណើរ** ទៅ និងមកពីការិយាល័យវេជ្ជបណ្ឌិតរបស់អ្នក ។

## តើនរណាខ្លះមានលក្ខណៈសម្បត្តិទទួលបានសំណងនិយោជិក?

- **និយោជិកស្ទើរតែទាំងអស់** ត្រូវបានរ៉ាប់រងដោយសំណងនិយោជិក - ដោយមិនគិតពីការងាររបស់អ្នក ម៉ោងធ្វើការរបស់អ្នក ស្ថានភាពការងាររបស់អ្នក ឬអ្នកត្រូវបានបង់ប្រាក់ឈ្នួលយ៉ាងដូចម្តេចឡើយ ។
- ម្ចាស់អាជីវកម្មត្រូវបានរ៉ាប់រង ប្រសិនបើពួកគេទិញគោលការណ៍ធានារ៉ាប់រងផ្ទាល់ខ្លួនរបស់ពួកគេតែប៉ុណ្ណោះ ។
- **និយោជករបស់អ្នកត្រូវតែបិទផ្សាយ** ឈ្មោះក្រុមហ៊ុនធានារ៉ាប់រងនៃសំណងនិយោជិករបស់ខ្លួន ។
- ប្រសិនបើអ្នកគិតថា និយោជករបស់អ្នកមិនមានសំណងនិយោជិកទេ សូមទូរស័ព្ទទៅលេខ 877-627-7233 ដើម្បីរាយការណ៍ ។ រាល់សេចក្តីរាយការណ៍រក្សាទុកជាអនាមិក ។






## របៀបទទួលបានអត្ថប្រយោជន៍នៃសំណងនិយោជិក

- **ប្រាប់និយោជករបស់អ្នក**ភ្លាម ប្រសិនបើអ្នករងរបួស ឬមានជម្ងឺបណ្តាលមកពីការងាររបស់អ្នក ។
- និយោជករបស់អ្នក ត្រូវតែជូនដំណឹងដល់ក្រុមហ៊ុនធានារ៉ាប់រងនៃសំណង និយោជិក អំពីអ្វីដែលបានកើតឡើងចំពោះអ្នក ។
- ក្រុមហ៊ុនធានារ៉ាប់រង នឹងផ្ញើរជូនអ្នកនូវលេខបណ្តឹងទាមទារ ។
- **ប្រាប់វេជ្ជបណ្ឌិតរបស់អ្នក** និងបុគ្គលិកនៅមណ្ឌលវេជ្ជសាស្ត្រថា បញ្ហាសុខភាពរបស់អ្នក គឺពាក់ព័ន្ធនឹងការងារ ហើយផ្តល់ជូនពួកគេនូវព័ត៌មានអំពីការធានារ៉ាប់រង ។
- វេជ្ជបណ្ឌិតរបស់អ្នក អាចទំនាក់ទំនងនិយោជករបស់អ្នកដោយផ្ទាល់ ប្រសិនបើអ្នកមិនមានលេខបណ្តឹងទាមទារ ។

## ប្រសិនបើនិយោជករបស់អ្នក មិនជូនដំណឹងក្រុមហ៊ុនធានារ៉ាប់រង ឬសំណងនិយោជិក ត្រូវបានបដិសេធ

- **ប្រសិនបើនិយោជករបស់អ្នកខកខានជូនដំណឹងក្រុមហ៊ុនធានារ៉ាប់រង** អំពីការរងរបួសរបស់អ្នក បន្ទាប់ពី 30 ថ្ងៃ ឬប្រសិនបើអ្នកមិនបានទទួលលេខបណ្តឹងទាមទារ អ្នកអាចដាក់បណ្តឹងទាមទាររបស់និយោជិក ។ សូមទៅកាន់ www.mass.gov/dia និងបំពេញទម្រង់ 110 ហើយផ្ញើរវាជាមួយនឹងព័ត៌មានវេជ្ជសាស្ត្រគាំទ្រណាមួយទៅកាន់ក្រសួងគ្រប់គ្រងគ្រោះថ្នាក់ឧស្សាហកម្ម (Department of Industrial Accidents - DIA) ។
- ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងនៃសំណងនិយោជិករបស់និយោជករបស់អ្នក **បដិសេធបណ្តឹងទាមទាររបស់អ្នក** អ្នកនឹងទទួលបានសេចក្តីជូនដំណឹងតាមរយៈប្រៃសណីយ៍ ។ អ្នកអាចតបតនឹងក្រុមហ៊ុនធានារ៉ាប់រង តាមរយៈការដាក់ជូនបណ្តឹងទាមទាររបស់និយោជិក ។ សូមទៅកាន់ www.mass.gov/dia និងបំពេញទម្រង់ 110 ហើយផ្ញើរទម្រង់ និងឯកសារគាំទ្រណាមួយទៅកាន់ក្រុមហ៊ុនធានារ៉ាប់រងនៃសំណងនិយោជិក និងទៅកាន់DIA ។

- ប្រសិនបើបណ្តឹងទាមទាររបស់អ្នក ត្រូវបានបដិសេធដោយក្រុមហ៊ុនធានារ៉ាប់រង យើងខ្ញុំសូមជូនយោបល់ថាឱ្យអ្នក**ស្វែងរកមេធាវី**ដែលមានបទពិសោធន៍ដោះស្រាយសំណុំរឿងសំណងនិយោជិក ដោយសារតែដំណើរការនេះ ជាញឹកញាប់មានភាពស្មុគ្រស្មាញ ។ ក្នុងករណីភាគច្រើនបំផុត មេធាវីត្រូវបានបង់ប្រាក់ជូន លុះត្រាតែពួកគេបានជោគជ័យទទួលបានអត្ថប្រយោជន៍របស់អ្នកតែប៉ុណ្ណោះ ។
- ទូរស័ព្ទទៅ 866-627-7577 សម្រាប់ជំនួយស្វែងរកមេធាវី ។ បុគ្គលិកនៅ DIA មិនអាចផ្តល់ជំនួយស្វែងរកមេធាវីបានទេ ។

## ការពារសិទ្ធិរបស់អ្នក

DIA ធ្វើការងារដើម្បីធ្វើឱ្យប្រាកដថា សិទ្ធិនៃសំណងនិយោជិករបស់អ្នក ត្រូវបានការពារ ។ ប្រសិនបើអ្នកជួបបញ្ហាណាមួយក្នុងចំណោមខាងក្រោម សូមទំនាក់ទំនងការិយាល័យស៊ើបអង្កេត (Office of Investigations) របស់ DIA តាមរយៈលេខ 877-627-7233 ។ (រាល់សេចក្តីរាយការណ៍ រក្សាទុកជាអនាមិក) ។

- និយោជកមិនមានការធានារ៉ាប់រងនៃសំណងនិយោជិក ។ អ្នកអាចពិនិត្យមើលថាតើនិយោជករបស់អ្នកមានការធានារ៉ាប់រងឬអត់តាមរយៈ www.mass.gov/dia ។ ចុចលើប៊ូតុង “Verify Workers’ Compensation Insurance” ។
- និយោជកបដិសេធជូនដំណឹងអ្នកអំពីក្រុមហ៊ុនធានារ៉ាប់រងនៃសំណងនិយោជិករបស់ខ្លួន ។
- និយោជកមិនលើកទឹកចិត្តអ្នកឱ្យដាក់បណ្តឹងទាមទារ បន្ទាប់ពីការរងរបួស ឬការមានជម្ងឺនៅកន្លែងធ្វើការ ។

វាគឺផ្ទុយនឹងច្បាប់រដ្ឋម៉ាស្សាឈូសិត ចំពោះនិយោជករបស់អ្នកក្នុងការបណ្តេញអ្នកចេញពីការងារ ដោយសារការដាក់បណ្តឹងទាមទារសំណងនិយោជិក ។ វាអាចជាការបំពាន លក្ខន្តិកៈនៃអ្នកជូនដំណឹងអំពី OSHA (OSHA whistleblower) ។

ច្បាប់អំពីអ្នកជាប់កិច្ចសន្យាឯករាជ្យ គឺមានភាពស្មុគស្មាញ ។ ប្រសិនបើអ្នកទទួលអារម្មណ៍ថានិយោជករបស់អ្នក បានចាត់ប្រភេទអ្នកមិនត្រឹមត្រូវ សូមស្វែងរកដំបូន្មានរបស់មេធាវី ។

